សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
១៦ ធ្នូ ២០១៥

- **សូមគោរព ឯកឧត្តមបណ្ឌិត ឆេង គឹមស៊ុន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**
- **សូមគោរព ឯកឧត្តម ពេជ្រ វាសនា អគ្គនាយករងកិច្ចការរដ្ឋបាលនៃក្រសួងធនធានទឹក និងឧតុនិយម**
- **សូមគោរព លោក កែវ វ៉យ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់**
- **សូមគោរព លោក ជុំ សុភី ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង**
- **សូមគោរព លោក ទុង ធីរម្យ អធិការរងនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនបីរួមមាន "គម្រោងស្តារប្រព័ន្ធធារាសាស្ត្រអន្លង់រូងក្នុងខេត្តពោធិ៍សាត់ គម្រោងស្តារឡើងវិញប្រឡាយរងស្តៅក្នុងខេត្តព្រៃវែង និងគម្រោងសាងសង់ទីស្នាក់ការអភិរក្សតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាលក្នុងខេត្តពោធិ៍សាត់" ។

ជំនួយទីមួយនេះ ផ្តល់ជូនសម្រាប់ពង្រីកផ្ទៃដីដាំដុះនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានថវិកាសរុប៨៩,៧៧៥ដុល្លារអាមេរិក។ គម្រោងនេះរួមមាន៖ ការស្តារប្រឡាយរង១ខ្សែប្រវែង ២,១០០ម៉ែត្រ ការសាងសង់សំណង់ក្បាលប្រឡាយរង១កន្លែង សំណង់លូជ្រុង១កន្លែង និងសំណង់លូបញ្ចេញទឹក៣កន្លែង។ យើងរំពឹងថា ប្រជាកសិករប្រមាណជា១,៥០០នាក់ នឹងទទួលបានទឹកស្រោចស្រពលើដីស្រែរបស់ពួកគេកាន់តែច្រើន បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

ជំនួយទីពីរនេះ ផ្តល់ជូនសម្រាប់ពង្រីកផ្ទៃដីដាំដុះនៅក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង ដែលមានថវិកាសរុប ៨៩,៤២៣ដុល្លារអាមេរិក។ គម្រោងនេះរួមមាន៖ ការស្តារប្រឡាយរង១ខ្សែប្រវែង ២,២៥០ម៉ែត្រ ការសាងសង់សំណង់បញ្ចូលទឹក១កន្លែង សំណង់ស្ទាក់ទឹក១កន្លែង និងសំណង់លូរំដោះទឹក២កន្លែង។ ជាមួយនឹងគម្រោងនេះ យើងរំពឹងថាប្រជាកសិករប្រមាណជា១,០០០នាក់ នឹងទទួលបានទឹកស្រោចស្រពលើដីស្រែរបស់ពួកគេ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

ជំនួយទីបីនេះ ផ្តល់ជូនដល់ខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ សម្រាប់ការសាងសង់ទីស្នាក់ការអភិរក្សតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្តាលខេត្តពោធិ៍សាត់មួយខ្នង ដែលមានថវិកាសរុបចំនួន៨៩,០៥០ដុល្លារអាមេរិក។ យើងរំពឹងថា គម្រោងនេះ នឹងផ្តល់ជូននូវទីស្នាក់ការយាមល្បាតមួយខ្នង២ជាន់ ដែលមាន១០បន្ទប់។ ទីស្នាក់ការនេះ នឹងជួយពង្រឹងនៃការយាមល្បាតពីការកាប់ព្រៃឈើខុសច្បាប់ ហើយនឹងផ្តល់អត្ថប្រយោជន៍ជូនដល់ប្រជាពលរដ្ឋដែលរស់នៅពឹងអាស្រ័យផល អនុផលព្រៃឈើ ប្រមាណជា៥,៤០០គ្រួសារផងដែរ។

ដោយទទួលស្គាល់ពីសារៈខាន់នៃវិស័យប្រព័ន្ធធារាសាស្ត្រ និងបរិស្ថាន រដ្ឋាភិបាលជប៉ុន បាននឹងកំពុងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជានៅក្នុងវិស័យទាំងនេះ តាមរយៈគម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

ខ្ញុំសង្ឃឹមថា គម្រោងទាំងបីនេះ ដែលបានចុះកិច្ចសន្យាផ្តល់ជំនួយនៅថ្ងៃនេះ នឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ជាមួយនឹងដៃគូររបស់យើង។ ខ្ញុំសង្ឃឹមថា សំណង់ខាងលើនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ ដើម្បីអោយប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅរួច។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

**សូមអរគុណ!**